**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## នីតិវិធី និងលក្ខខណ្ឌ

## ការគ្រប់គ្រងការប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

## របស់កងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ និងមន្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៨

## ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីនីតិវិធី និងលក្ខខណ្ឌការគ្រប់គ្រង ការប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ របស់កងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ និងមន្ត្រី ដូចមានចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលបំណងការពារសន្តិសុខ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់ លើការគ្រប់គ្រង ការប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ របស់កងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ និងមន្ត្រី ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗ ក្នុងអនុក្រឹត្យនេះ មានន័យដូចខាងក្រោម ÷

អាវុធ សំដៅដល់ កាំភ្លើងមានកាណុង មានគន្លឹះកៃ ដែលគេផលិត ឬ កែច្នៃសម្រាប់បាញ់បញ្ចេញក្បាលគ្រាប់ គ្រាប់ប្រាយ គ្រាប់បែក គ្រាប់ផ្លោង គ្រាប់កាំជ្រួច គ្រាប់ព្រួញ វត្ថុរាវ ឧស្ម័ន កាំរស្មី សារធាតុគីមី ជីវសាស្ត្រ ដោយប្រើកម្លាំងរំសេវផ្ទុះ កម្លាំងរ៉ឺស័រ កម្លាំងខ្យល់ ឬ ឧស្ម័ន ឬ កាំរស្មី ។

ត្រូវរាប់បញ្ចូលជាផ្នែកមួយ របស់កាំភ្លើងផងដែរ នូវគ្រឿងបន្លាស់ ឬ គ្រឿងផ្គុំសំខាន់ៗ ដែលផលិតឡើងក្នុងគោលដៅ អាចផ្គុំធ្វើឱ្យទៅជាកាំភ្លើង ឬ បង្កើនប្រសិទ្ធភាពរបស់កាំភ្លើង ដូចជា ស្នូកកាំភ្លើង កាណុង ប្រអប់កៃ បង់គ្រាប់ កែវយឹតតម្រង់ កែវកាំរស្មីឆ្លុះតម្រង់ និង បំពង់ខ្ទប់សំឡេង ។

គ្រឿងផ្ទុះ សំដៅដល់ គ្រាប់បែកទម្លាក់ គ្រាប់បែកដៃ គ្រាប់បែកបង្កៃ គ្រាប់មីន គីបផ្ទុះ ខ្សែឆេះផ្ទុះ ខ្សែឆេះយឺត រំសេវ ជាតិផ្ទុះ សារធាតុផ្ទុះគ្រប់ប្រភេទ ទោះមានដើមកំណើតពីអ្វីក៏ដោយ ដែលអាចធ្វើឱ្យផ្ទុះបាន ។

គ្រាប់រំសេវ សំដៅដល់ គ្រាប់កាំភ្លើងធំ តូច គ្រាប់កាំជ្រួច ដែលមានសមាសធាតុ សំបកគ្រាប់ "ឡូត" រំសេវ ឬ សាស់បញ្ជូន ក្បាលគ្រាប់ កិប ។

## ជំពូកទី ២

## នីតិវិធី និង លក្ខខណ្ឌក្នុងការគ្រប់គ្រង និងការអនុញ្ញាតឱ្យប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវ

**មាត្រា ៥.-**

អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ត្រូវចុះបញ្ជីគ្រប់គ្រងតាមគំរូឯកភាពកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃសម្រាប់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ និងមន្ត្រី ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិសម្រាប់កងយោធពលខេមរភូមិន្ទ។

អាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ ដែលមិនមានចុះក្នុងបញ្ជីគ្រប់គ្រង ត្រូវចាត់ជាអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវខុសច្បាប់ ដែលត្រូវប្រមូលដកហូតទុកជាទ្រព្យសម្បត្តិរដ្ឋ ។

អាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ ដែលត្រូវបានរឹបអូស តាមអំណាចសាលក្រម ឬ សាលដីការបស់តុលាការ ត្រូវបង្វែរមកក្រសួងមហាផ្ទៃ បើទាក់ទងដល់បទល្មើសស៊ីវិល ឬ ក្រសួងការពារជាតិ បើទាក់ទងដល់បទល្មើសយោធា។ ការរក្សាទុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវទាំងនោះ ត្រូវកំណត់ដោយក្រសួងមហាផ្ទៃ និង ឬ ក្រសួងការពារជាតិ។

អាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវដែលអាចដាក់តាំងពិព័រណ៍បាន លុះត្រាមានលិខិតអនុញ្ញាត ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ និង ឬ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦.-**

ស្ថាប័នសាធារណៈ និងមន្ត្រី អាចត្រូវបានអនុញ្ញាត ឱ្យប្រើប្រាស់អាវុធខ្លី វែង ដើម្បីការពារក្រសួង ស្ថាប័ន ការពារទ្រព្យសម្បត្តិរដ្ឋ ឬ ការពារខ្លួនក្នុងពេលប្រតិបត្តិការ ។

មន្ត្រីដែលប្រើប្រាស់អាវុធនេះ មិនត្រូវរៀបចំជាកងឯកភាពរៀបរយ ដូចកងយោធពលខេមរភូមិន្ទ ឬ កងកម្លាំងនគរបាលជាតិទេ ។

**មាត្រា ៧.-**

តាមសំណើរបស់ក្រសួង ស្ថាប័នសាធារណៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ មន្ត្រីដែលបានទទួលសិទ្ធិប្រទាន ពិនិត្យសម្រេចលើបរិមាណ ប្រភេទ គុណភាពអាវុធ គ្រាប់រំសេវ ដែលត្រូវផ្តល់ឱ្យប្រើប្រាស់។

**មាត្រា ៨.-**

ត្រូវបានអនុញ្ញាតឱ្យមន្ត្រី ដែលកំពុងមានឋានៈ តួនាទី កាន់កាប់ប្រើប្រាស់អាវុធខ្លី យកតាមខ្លួនមួយនាក់ មួយដើម និងគ្រាប់មិនលើសពី ០២ បង់ តាមការកំណត់ដូចខាងក្រោម ៖

- ប្រធាន អនុប្រធាន និងសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការនៃក្រសួងព្រះបរមរាជវាំង
- ប្រធាន អនុប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ប្រធាន អនុប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ប្រធានតុលាការរាជធានី ខេត្ត និងព្រះរាជអាជ្ញាអមតុលាការរាជធានី ខេត្ត
- សមាជិករាជរដ្ឋាភិបាល អគ្គលេខាធិការរាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គលេខាធិការ អគ្គាធិការ និងមន្ត្រីដែលកំពុងមានឋានៈ តួនាទីស្មើនឹងមុខតំណែងទាំងនេះនៃក្រសួង ស្ថាប័នសាធារណៈ
- អភិបាល អភិបាលរងរាជធានី ខេត្ត និង អភិបាលក្រុង ស្រុក ខណ្ឌ
- សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៩.-**

ប្រធានក្រសួង ស្ថាប័នសាធារណៈ ដែលបានទទួលការអនុញ្ញាត ឱ្យប្រើប្រាស់អាវុធខ្លី វែង

និងគ្រាប់ មានភារៈទទួលខុសត្រូវដូចតទៅ ÷

-ចំពោះអាវុធខ្លី គ្រាប់ ដែលបានអនុញ្ញាតឱ្យប្រើប្រាស់យកតាមខ្លួន ត្រូវប្រមូលប្រគល់ឱ្យក្រសួងមហាផ្ទៃរក្សាទុក ក្នុងករណីមន្ត្រីនោះ អស់នីតិសម្បទា ឬ មរណៈ

-ចំពោះអាវុធខ្លី វែង និងគ្រាប់ ដែលបានអនុញ្ញាតឱ្យប្រើប្រាស់ជាអង្គភាព ពេលប្រតិបត្តិការត្រូវមានលិខិតបញ្ជាបេសកកម្ម និងប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធភ្ជាប់ជាមួយ ។ ក្រោយចប់ប្រតិបត្តិការភ្លាមត្រូវយកអាវុធ គ្រាប់ និងប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ មករក្សាទុកក្នុងអង្គភាពវិញ

-ត្រូវចាត់មន្ត្រីទទួលខុសត្រូវគ្រប់គ្រងអាវុធ គ្រាប់ និង ត្រូវមានឃ្លាំងសុវត្ថិភាពសម្រាប់ទុកដាក់

-រយៈពេល ៦ ខែម្តង ត្រូវធ្វើរបាយការណ៍ ស្តីពីសភាពការណ៍ប្រែប្រួលអាវុធ គ្រាប់ មកក្រសួងមហាផ្ទៃ ។

**មាត្រា ១០.-**

មន្ត្រីត្រូវបង្ហាញអាវុធ គ្រាប់ ប័ណ្ណសម្គាល់ និង ឬ លិខិតបញ្ជាបេសកកម្ម ដល់ភ្នាក់ងារមានសមត្ថកិច្ច នៅពេលមានសំណូមពរត្រួតពិនិត្យ ។

**មាត្រា ១១.-**

កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ដែលត្រូវបានអនុញ្ញាតឱ្យកាន់កាប់ប្រើប្រាស់អាវុធខ្លី យកតាមខ្លួន មួយនាក់ មួយដើម និង គ្រាប់ មិនលើសពី ០២ បង់ ត្រូវកំណត់ឋានន្តរសក្តិ ឬ មុខតំណែងដូចខាងក្រោម ÷

ក-ឋានន្តរសក្តិ

-មានឋានន្តរសក្តិ ពីថ្នាក់វរសេនីយ៍ឯកឡើង

ខ-មុខតំណែង

-អនុប្រធាននាយកដ្ឋានឡើង

-ស្នងការនគរបាលរាជធានី ខេត្ត

-មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត

-មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត

-មេបញ្ជាការកងវរសេនាធំ

-មេបញ្ជាការកងវរសេនាតូច

-អធិការនគរបាលក្រុង ស្រុក ខណ្ឌ

-មេបញ្ជាការផ្នែកសឹករងក្រុង ស្រុក ខណ្ឌ

-មេបញ្ជាការកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ ។

មេបញ្ជាការ ឬ ប្រធានអង្គភាព មានភារៈទទួលខុសត្រូវប្រមូល ឬ ប្រគល់អាវុធ គ្រាប់ទាំងនេះមកអង្គភាពវិញ ក្នុងករណីអស់នីតិសម្បទា ឬ មរណៈ ។

**មាត្រា ១២.-**

កងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ ក្នុងពេលប្រតិបត្តិការ អាចត្រូវបាន អនុញ្ញាតឱ្យប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវរបស់អង្គភាព តែត្រូវមានលិខិតបញ្ជាបេសកកម្ម និងប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ ភ្ជាប់មកជាមួយ ។

ក្រោយចប់ប្រតិបត្តិការភ្លាម ត្រូវយកអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ មកប្រគល់ឱ្យអង្គភាពវិញ ។

**មាត្រា ១៣.-**

ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ មានពីរប្រភេទ និងមានសុពលភាព ដូចខាងក្រោម ÷

- ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធខ្លីយកតាមខ្លួន មានសុពលភាព មួយឆ្នាំ គិតពីថ្ងៃដែលបានចេញប័ណ្ណ
- ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធខ្លី វែងរបស់អង្គភាពមានសុពលភាព ពីរឆ្នាំ គិតពីថ្ងៃដែលបានចេញប័ណ្ណ សម្រាប់កងកម្លាំងនគរបាលជាតិ និងស្ថាប័នសាធារណៈ
- ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធខ្លីរបស់អង្គភាព មានសុពលភាព មួយឆ្នាំ គិតពីថ្ងៃដែលបានចេញប័ណ្ណ សម្រាប់កងយោធពលខេមរភូមិន្ទ ។

ខ្លឹមសារ និង រូបភាព របស់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ១៤.-**

បែបបទនៃការស្នើសុំប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធត្រូវកំណត់ដូចខាងក្រោម ÷

ក- ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធខ្លីយកតាមខ្លួន :

- ពាក្យស្នើសុំអាវុធ គ្រាប់ "តាមគំរូឯកភាព"
- ពាក្យសុំប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធខ្លីយកតាមខ្លួន "តាមគំរូឯកភាព"
- លិខិតបញ្ជាក់ពីឋានន្តរសក្តិ ឬ ឋានៈមុខតំណែង
- រូបថតចំពីមុខរបស់សាមីជន "ពណ៌ធម្មជាតិ" ។

ខ- ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធខ្លី វែងរបស់អង្គភាព :

- សំណើសុំអាវុធ គ្រាប់
- សំណើសុំប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធខ្លី វែងរបស់អង្គភាពមានបញ្ជាក់ពីមូលហេតុ និងភាពចាំបាច់ដែលត្រូវប្រើប្រាស់ ។

គំរូលិខិត បញ្ជី និងបែបបទក្នុងការដាក់ពាក្យ ឬ សំណើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ១៥.-**

រដ្ឋមន្ត្រីក្រសួងការពារជាតិ ឬ មន្ត្រីដែលបានទទួលសិទ្ធិប្រទាន ជាអ្នកចុះហត្ថលេខាលើប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ របស់កងយោធពលខេមរភូមិន្ទ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ មន្ត្រីដែលបានទទួលសិទ្ធិប្រទាន ជាអ្នកចុះហត្ថលេខាលើប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ របស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ និងមន្ត្រី ។

ការប្រទានសិទ្ធិចុះហត្ថលេខានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ។

## ជំពូកទី ៣

## ការនាំចូល ការនាំចេញ

## ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

**មាត្រា ១៦.-**

ការនាំចូល ការនាំចេញអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវត្រូវមានការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល តាមសំណើ ÷

- រដ្ឋមន្ត្រីក្រសួងការពារជាតិ បើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវនោះ បម្រើឱ្យវិស័យការពារជាតិ ឬ
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវនោះ បម្រើឱ្យវិស័យការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា ១៧.-**

ការសុំអនុញ្ញាតឱ្យអង្គរក្សបរទេសយកអាវុធ និងគ្រាប់រំសេវ ចូលមកកម្ពុជា ដើម្បីការពារដំណើរទស្សនកិច្ចរបស់ព្រះមហាក្សត្រ ឬ មហាក្សត្រិយានី ប្រធានាធិបតី ប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី ឬ ឥស្សរជនជាន់ខ្ពស់ ត្រូវសម្រេចយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ឬ មន្ត្រីដែលបានទទួលសិទ្ធិប្រទាន។

**មាត្រា ១៨.-**

ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ត្រូវមានការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល តាមសំណើ ÷

- រដ្ឋមន្ត្រីក្រសួងការពារជាតិ បើការដឹកជញ្ជូនឆ្លងកាត់នោះ បម្រើវិស័យការពារជាតិ និង ឬ
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើការដឹកជញ្ជូនឆ្លងកាត់នោះបម្រើវិស័យការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ។

កិច្ចប្រតិបត្តិការអមការពារ ការដឹកជញ្ជូនឆ្លងកាត់នោះ ត្រូវធានាសុវត្ថិភាព និងនិរភ័យផ្សេងៗពីសាមីក្រសួងដែលស្នើឡើង។

**មាត្រា ១៩.-**

ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ក្នុងផ្ទៃប្រទេស ត្រូវបានកំណត់ដូចខាងក្រោម ÷

- ក្នុងគោលដៅការពារជាតិ ត្រូវមានលិខិតអនុញ្ញាត ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬ មន្ត្រីដែលបានទទួលសិទ្ធិប្រទាន
- ក្នុងគោលដៅការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ត្រូវមានលិខិតអនុញ្ញាត ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ មន្ត្រីដែលបានទទួលសិទ្ធិប្រទាន។

លក្ខខណ្ឌបច្ចេកទេស ដើម្បីធានាសុវត្ថិភាពនិរភ័យ ក្នុងការដឹកជញ្ជូនត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ។

## ជំពូកទី ៤
## ក្លឹប ទីលានហាត់ហ្វឹកហ្វឺន រោងជាង និង ទីតាំងសាកល្បងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

**មាត្រា ២០.-**

ក្លឹប ឬ ទីលានសម្រាប់ហាត់បាញ់ដើម្បីហ្វឹកហ្វឺន ឬ រោងជាងជួសជុល ឬ ទីតាំងសម្រាប់ធ្វើការសាកល្បងគុណភាពអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ បម្រើវិស័យការពារជាតិ ត្រូវស្ថិតនៅក្នុងមូលដ្ឋាននៃកងយោធពលខេមរភូមិន្ទ និង ត្រូវបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

ក្លឹប ឬ ទីលានសម្រាប់ហាត់បាញ់ ដើម្បីហ្វឹកហ្វឺន ឬ រោងជាងជួសជុល ឬ ទីតាំងសម្រាប់ធ្វើការសាកល្បងគុណភាពអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ បម្រើវិស័យការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ត្រូវស្ថិតនៅក្នុងមូលដ្ឋាន នៃកងកម្លាំងនគរបាលជាតិ និង ត្រូវបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

- ក្លឹប ឬ ទីលានសម្រាប់ហាត់បាញ់ដើម្បីហ្វឹកហ្វឺន ឬ រោងជាងជួសជុល ឬ ទីតាំងសម្រាប់ធ្វើការសាកល្បងគុណភាពអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវទាំងនោះ ត្រូវស្របតាមលក្ខណៈបច្ចេកទេស និងធានាសុវត្ថិភាពសាធារណៈ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ២១.-**

អនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យ ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលរាជធានី អភិបាលខេត្ត ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*